អន្តរប្រិយ៍
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ពុទ្ធភាសិតមួយបទពោលថា អត្តា ហិ អត្តនោ នាថោ ប្រែថាខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន ។

website: www.hoksavann.org

ថ្ងៃទី១ ឧសភា ២០០៨



ពុទ្ធភាសិតថា ខ្លួនជាទីពឹងរបស់ខ្លួន ពុំមែនព្រះពុទ្ធទទួលស្គាល់ថា មានអត្តា ដូចជាសាសនាព្រាហ្មណ៍ដែលយល់ថា នៅក្នុងខ្លួនមនុស្សសត្វ មានអត្តាគឺខ្លួន ឬព្រលឹងវិញ្ញាណពុំអាចរលត់នោះឡើយ ។ ព្រះអង្គមានញាណ ឃើញតាមសេចក្ដីពិតថា ខ្លួនមនុស្សសត្វដែលប្រកបដោយខន្ធ៥ មានរូបខន្ធជាដើមនេះ ជាអនត្តាពុំមែនខ្លួន ព្រោះជាសង្ខារប្រព្រឹត្តទៅដោយខ្លួនវា តាមច្បាប់ធម្មជាតិមិនស្ដាប់បង្គាប់ ។ ចំណែកអត្តាក្នុងពុទ្ធភាសិតនេះ សំដៅយកខ្លួនដែលផ្សេងពីអ្នកដទៃ ហើយសកម្មភាពល្អគ្រប់យ៉ាង ត្រូវធ្វើដោយខ្លួនឯង ដូចពុទ្ធភាសិតមួយបទទៀតពោលថា សេចក្ដីបរិសុទ្ធក្ដី ពុំបរិសុទ្ធក្ដី ត្រូវកើតចេញមកពីខ្លួនឯង អ្នកដទៃពុំអាចញ៉ាំងអ្នកដទៃឲ្យបរិសុទ្ធ និងមិនបរិសុទ្ធបានឡើយ ។ ពាក្យថាខ្លួនជាទីពឹងរបស់ខ្លួននេះ ដកចេញពីពុទ្ធភាសិតទាំងមូលថា ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន អ្នកដទៃនឹងជាទីពឹងដូចម្ដេចបាន បើបុគ្គលមានខ្លួនទូន្មានល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។ ត្រង់នេះមានន័យដ៏ជ្រៅថា អ្នកដែលបានខ្លួនទូន្មានរហូតបានសំរេចជាព្រះអរហន្ត ជាថ្នាក់ខ្ពស់របស់ព្រះពុទ្ធសាសនា ក៏ដោយសារការប្រតិបត្តិតាមធម៌ គឺសីលសមាធិបញ្ញាដោយខ្លួនឯង ។ ពុទ្ធបរិស័ទតែងសូត្រថា យកព្រះពុទ្ធព្រះធម៌ និងព្រះសង្ឃជាទីពឹងទីរលឹកស្មើដោយជីវិតនោះ មានន័យថា ជឿការត្រាស់ដឹងរបស់ព្រះអង្គ ជឿព្រះធម៌ជាធម៌ចេញចាកទុក្ខ ជឿព្រះសង្ឃជាអ្នកប្រតិបត្តិដ៏ត្រឹមត្រូវតាមមគ្គ ប្រកបដោយអង្គ៨ ។ បន្ទាប់ពីមានជំនឿដូច្នេះហើយ ក៏ខំប្រតិបត្តិតាមព្រះធម៌ ដែលព្រះអង្គសំដែងប្រាប់ ពុំមែនពឹងព្រះពុទ្ធឲ្យព្រះអង្គជួយឲ្យសំរេចមគ្គផលថ្នាក់ណាមួយឡើយ ព្រះអង្គគ្រាន់តែបង្ហាញធម៌ប្រតិបត្តិប៉ុ

ណ្ណោះ បើចង់បានសំរេចមគ្គផលថ្នាក់ណាមួយ ត្រូវប្រតិបត្តិដោយខ្លួនឯង ។ មួយទៀត ដូចគ្រូបង្រៀននិងសាស្ត្រាចារ្យមានភារកិច្ចត្រឹមតែពន្យល់ណែនាំសិស្សនិងនិស្សិតតាមមុខវិជ្ជាបង្រៀន ត្រូវសិស្សនិងនិស្សិតខំប្រឹងប្រែងស្តាប់លោកពន្យល់ និងធ្វើកិច្ចការដែលលោកដាក់ឲ្យ ទើបអ្នកសិក្សាមានការចេះដឹង ពុំមែនគ្រូជួយឲ្យចេះ ដោយសិស្សពុំបានប្រឹងប្រែងសិក្សារៀនសូត្រនោះឡើយ ។ ពិតមែនតែមនុស្សក្នុងលោករស់នៅ តែងតែពឹងពាក់គ្នាទៅវិញទៅមក ដូចម្តាយឪពុកកូនចៅប្តីប្រពន្ធ គ្រូនិងសិស្ស អ្នកដឹកនាំនិងប្រជាពលរដ្ឋ ព្រះសង្ឃនិងគ្រហស្ថ ប្រទេសនីមួយៗនិងអង្គការសហប្រជាជាតិជាដើម តែងពឹងពាក់គ្នា តែងជួយឧបត្ថម្ភគ្នា ប៉ុន្តែជាការជួយម្តងម្កាល ពុំអាចជួយជានិច្ចឡើយ ជាការជួយខាងក្រៅ ហើយអ្នកដែលគេអាចជួយ លុះត្រាតែមានលក្ខណៈគួរគេជួយ ឯការជួយនោះ គ្រាន់តែជាការជួយឧបត្ថម្ភប៉ុណ្ណោះ ត្រូវតែខ្លួនឯងជួយខ្លួនឯង ។ សុភាសិតរបស់ពួកបស្ចិមប្រទេសក៏មាននិយាយថា ដើម្បីឲ្យទេវតាជួយអ្នក អ្នកត្រូវជួយខ្លួនអ្នកជាមុនសិន ។

ពាហិរសាសនា គឺសាសនាខាងក្រៅពីព្រះពុទ្ធសាសនានិយាយថា ព្រះអាទិទេពមានអំណាចឲ្យសុខឲ្យទុក្ខ ឲ្យឡើងឋានសួគ៌ឲ្យចុះនរកដល់មនុស្សសត្វ ។ បើមនុស្សសត្វជឿព្រះអង្គ ធ្វើឲ្យព្រះអង្គសព្វព្រះទ័យ ព្រះអង្គឲ្យកើតក្នុងឋានសួគ៌ បើមិនជឿព្រះអង្គធ្វើឲ្យព្រះអង្គខ្ញាល់ ព្រះអង្គនឹងឲ្យធ្លាក់នរក ។ សុខទុក្ខចំរើនវិនាសនរកសួគ៌កើតចេញពីព្រះអាទិទេព ពុំមែនកើតឡើងពីអំពើល្អអាក្រក់របស់មនុស្សសត្វ កសាងដោយខ្លួនឯងខ្លួនទីពឹងខ្លួន ដូចព្រះពុទ្ធសាសនាពោលឡើយ ។ ទស្សនៈរបស់ពាហិរសាសនានេះពុំមែនភស្តុតាងបញ្ជាក់ជាការពិតឡើយ ចំណែកព្រះពុទ្ធសាសនាវិញ ដូចបានពោលមកហើយ អ្វីទាំងអស់កើតពីកម្មផលឬហេតុផលតាមសភាពខ្លួនវា មានលក្ខណៈជាសាកលតាមច្បាប់ធម្មជាតិ ដែលគេអាចពិសោធឃើញការពិតបានក្នុងជីវិតបច្ចុប្បន្ន ។

ក្រុមអ្នកស្រាវជ្រាវវិទ្យាសាស្ត្របានទទួលស្គាល់តម្លៃរបស់ព្រះពុទ្ធសាសនាថា មានហេតុផលពិត ស្របតាមលក្ខណៈវិទ្យាសាស្ត្រដែលខ្លួនបានពិសោធឃើញ ដូចមនុស្សឈឺ កើតឡើងពីហេតុ គឺមេរោគតាមប្រភេទរបស់ជម្ងឺជាដើម ។ ដរាបណាវិទ្យាសាស្ត្រចេះតែលូតលាស់ ដរាបនោះព្រះពុទ្ធសាសនាចេះតែបង្ហាញការពិតកាន់តែច្បាស់លាស់ឡើង ។ គេសង្កេតឃើញថា ចំនួនអ្នកកាន់ពាហិរសាសនានៅបស្ចិមប្រទេស គឺនៅលោកខាងលិច ដូចជាសហរដ្ឋអាមេរិក កាណាដា បារាំងជាដើម បានត្រូវថយចុះ ហើយចំនួនអ្នកកាន់ព្រះពុទ្ធសាសនាកាន់តែចំរើនឡើង ។ ដូច្នេះហើយបានជាបេសកជនរបស់ពាហិរសាសនាបានងាកទៅបញ្ចុះបញ្ចូលអូសទាញប្រជាជននៅប្រទេសអាស៊ីដែលកំពុងមានវិបត្តិដូចជាប្រទេសកម្ពុជាជាដើម ដោយមធ្យោបាយចែកអំណោយ និងបង្រៀនភាសាអង់គ្លេស ជានុយបញ្ឆោតឲ្យជឿសាសនារបស់ខ្លួន ព្រោះពុំអាចផ្សាយនៅក្នុងប្រទេ

សលោកខាងលិច ឲ្យគេជឿបានទៀតឡើយ ។ សម័យបារាំងធ្វើអាណានិគមនិយមលើប្រទេសកម្ពុជា បារាំងគ្រីក្បាលដោយពោលថា ខ្មែរក្បាលរឹងណាស់ មិនងាយអូសទាញឲ្យជឿសាសនាឯទៃទៀត ក្រៅពីព្រះពុទ្ធសាសនាឡើយ ។ល។

❇ ❇

❇